ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ៣៦០១៩-គ្រក.សរ.សរជ

# សារាចរ
# ស្តីពី
# នីតិវិធី និងដំណើរការនៃការទទួលពាក្យស្នើសុំ ការពិនិត្យ និងវាយតម្លៃ និងការឆ្លើយតបលើពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក (ធនធានរ៉ែ)

ដើម្បីជំរុញ និងអភិវឌ្ឍវិស័យឧស្សាហកម្មរ៉ែនៅកម្ពុជា និងដើម្បីរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនោះ ការផ្តល់អាជ្ញាបណ្ណស្វែងរុករកដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដើម្បីស្វែងរុករកធនធានរ៉ែគ្រប់ប្រភេទនៅតាមតំបន់នានានៃបណ្តាខេត្តនៅកម្ពុជាមានសារៈសំខាន់ណាស់ ដើម្បីកំណត់ប្រភពធនធាន និងសក្តានុពលថ្មី សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបម្រើផលប្រយោជន៍ជូនប្រជាជនកម្ពុជាគ្រប់រូបនៅថ្ងៃអនាគត ។

សារាចរនេះមានគោលបំណងកំណត់អំពី៖

(១) នីតិវិធី និងដំណើរការនៃការទទួលពាក្យស្នើសុំ ការពិនិត្យនិងវាយតម្លៃ និងការឆ្លើយតបលើពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ។

(២) ការផ្តល់អាជ្ញាបណ្ណស្វែងរុករក ដោយផ្អែកលើការពិនិត្យវាយតម្លៃឲ្យបានសមស្របនូវលក្ខណៈសេដ្ឋកិច្ច និងសង្គមនៃគម្រោងប្រតិបត្តិការស្វែងរុករក ស្របតាមគោលការណ៍នៃការអភិវឌ្ឍ និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងភាពទទួលខុសត្រូវ ។

(៣) ប្រសិទ្ធភាពនៃការឆ្លើយតបក្នុងការផ្តល់សេវាសាធារណៈពាក់ព័ន្ធជាមួយនឹងការដាក់ពាក្យ និងការពិនិត្យសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ។

ដូច្នេះ ការផ្តល់អាជ្ញាបណ្ណស្វែងរុករកក៏ត្រូវឆ្លងកាត់ការពិនិត្យ និងវាយតម្លៃជាមុន ឲ្យបានច្បាស់លាស់អំពីសង្គតិភាពជាមួយផែនការប្រើប្រាស់ដីធ្លី ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ផលប្រយោជន៍សេដ្ឋកិច្ចសង្គម សុវត្ថិភាព និងសុខុមាលភាពនៃបរិស្ថាន និងសង្គម ផងដែរ ។

ដើម្បីឲ្យការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ក្រសួងរ៉ែ និងថាមពល សូមដាក់ចេញនូវនីតិវិធីនៃការពិនិត្យ និងវាយតម្លៃ និងសម្រេចឆ្លើយតបលើពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ដូចខាងក្រោម ៖

## ១. ការពិគ្រោះយោបល់

ការពិនិត្យ និងវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ត្រូវមានការសិក្សា និងពិគ្រោះយោបល់ត្រឹមត្រូវជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ សហគមន៍មូលដ្ឋាន និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា តាមការចាំបាច់ និងស្របតាមការតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធជាធរមាន។



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ក្នុងករណីចាំបាច់ នាយកដ្ឋានទទួលបន្ទុកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អាចធ្វើការតម្រូវឲ្យអ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងជំនាញការពាក់ព័ន្ធរបស់ខ្លួនមកធ្វើការបំភ្លឺបញ្ហាបច្ចេកទេសនានានៅក្នុងពាក្យស្នើសុំអាជ្ញាបណ្ណ និងគម្រោងផែនការកម្មវិធីការងារ ដែលបានស្នើឡើង និង/ឬ ចាត់មន្ត្រីជំនាញចុះពិនិត្យ និងវាយតម្លៃដល់ទីតាំងផ្ទាល់បន្ថែមទៀត។

## ២. ឯកសារពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ជាឯកសារសាធារណៈ

ឯកសារពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក និងឯកសាររបាយការណ៍ពាក់ព័ន្ធ ដែលបានដាក់ស្នើសុំមកក្រសួងរ៉ែ និងថាមពល គឺជាឯកសារសាធារណៈ ដែលអាចដាក់ជូនឲ្យសាធារណៈជនទូទៅពិនិត្យបាន តាមការស្នើសុំ ។ ប្រសិនបើមានព័ត៌មានសម្ងាត់ដែលតម្រូវលាក់ការណ៍ អ្នកដាក់ពាក្យស្នើសុំត្រូវរៀបចំចងក្រងព័ត៌មានសម្ងាត់ទាំងនោះក្នុងឯកសារដោយឡែក ជាឧបសម្ព័ន្ធនៃឯកសារគម្រោងផែនការស្វែងរុករក ហើយត្រូវបញ្ជាក់លើឯកសារទាំងនោះថាជា «ព័ត៌មានសម្ងាត់» ។ អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់អំពីការតម្រូវឲ្យរក្សាព័ត៌មានសម្ងាត់ទាំងនេះ ។

## ៣- នីតិវិធី និងដំណើរការនៃការពិនិត្យ និងវាយតម្លៃលើពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក

នៅមុនពេលបើកឲ្យមានការទទួលពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកនៅតំបន់ថ្មីណាមួយ ក្រសួងរ៉ែ និងថាមពលនឹងចាត់ឲ្យមានការសិក្សាវាយតម្លៃបឋមមួយ ដើម្បីកំណត់សង្គតិភាពនៃផែនការប្រើប្រាស់ដីធ្លី លក្ខណៈនៃផលប៉ះពាល់សេដ្ឋកិច្ចសង្គម និងតម្រូវការយន្តការសម្របសម្រួលចាំបាច់នានា ដើម្បីអាចអនុញ្ញាតឲ្យប្រតិបត្តិការស្វែងរុករករ៉ែអាចដំណើរការទៅបាន ។ តាមតម្រូវការចាំបាច់របស់ខ្លួន ក្រសួងរ៉ែ និងថាមពលអាចអនុញ្ញាតឲ្យរូបវន្តបុគ្គល ឬនិតិបុគ្គល ធ្វើការសិក្សាវាយតម្លៃបឋមនេះ ដែលជាផ្នែកមួយដើម្បីរៀបចំបំពេញឯកសារស្នើសុំអាជ្ញាបណ្ណស្វែងរុករកធនធានរ៉ែ ។

ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក និងដំណើការនីតិវិធីនៃការពិនិត្យ និងវាយតម្លៃ ត្រូវអនុវត្តជាជំហានៗ ដូចមានកំណត់ក្នុងគំនូសបំព្រួញ និងសេចក្ដីពន្យល់បន្ថែមដូចខាងក្រោមនេះ ៖

ក- ឯកសារពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ត្រូវរៀបចំដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងស្នើសុំធ្វើការស្វែងរុករកធនធានរ៉ែឲ្យបានត្រឹមត្រូវ និងពេញលេញ ស្របតាមការតម្រូវកំណត់ក្នុងប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ។

ខ- ពាក្យស្នើសុំត្រូវដាក់នៅការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងរ៉ែ និងថាមពល ដោយមានភ្ជាប់ជាមួយនូវគ្រប់ឯកសារ និងព័ត៌មានដែលបានតម្រូវ ។

គ- សំណុំឯកសារពាក្យស្នើសុំ នឹងត្រូវត្រួតពិនិត្យលើភាពពេញលក្ខណៈនៃការបំពេញព័ត៌មាន និងឯកសារភ្ជាប់ ស្របតាមការតម្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល នៅការិយាល័យច្រកចេញចូលតែមួយ នៅចំពោះមុខអ្នកដាក់ពាក្យស្នើសុំ ។ ក្នុងករណីពិនិត្យឃើញសំណុំឯកសារពាក្យស្នើសុំពុំមានលក្ខណៈគ្រប់គ្រាន់ និងពេញលេញស្របតាមការតម្រូវ ការិយាល័យច្រកចេញចូលតែមួយត្រូវចេញដីកាបញ្ជូនឯកសារពាក្យស្នើសុំ ត្រឡប់ឲ្យអ្នកដាក់ពាក្យស្នើសុំវិញភ្លាម ។ ក្នុងករណីពិនិត្យឃើញសំណុំឯកសារពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងពេញលេញស្របតាមការតម្រូវ ការិយាល័យច្រកចេញចូលតែមួយ ត្រូវចាត់ចែងតម្រូវឲ្យមានការបង់កម្រៃ

សេវាសាធារណៈនៃការទទួលពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ស្របតាមការកំណត់របស់ប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងរ៉ែ និងថាមពល។

ឃ- ការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើការចុះបញ្ជីទទួលពាក្យស្នើសុំ និងចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ផ្តល់ជូនអ្នកដាក់ពាក្យស្នើសុំភ្លាមៗ ក្រោយពីមានការទូទាត់បង់កម្រៃសេវាសាធារណៈ សម្រាប់ការទទួលពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក ដោយអ្នកដាក់ពាក្យស្នើសុំរួចហើយ ។

ង- សំណុំឯកសារពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកដែលបានចុះបញ្ជីទទួលពាក្យរួចហើយ នឹងត្រូវធ្វើការបញ្ជូនតាមគោលការណ៍រដ្ឋបាលផ្ទៃក្នុង មកនាយកដ្ឋានទទួលបន្ទុកពិនិត្យ និងវាយតម្លៃលើទម្រង់ប្រតិបត្តិការស្វែងរុករក កម្មវិធីការងារ សមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុរបស់អ្នកដាក់ពាក្យស្នើសុំ និងភាពអនុលោមស្របតាមបទប្បញ្ញត្តិនានាជាធរមាន តាមជំហានដូចតទៅ៖

១- នាយកដ្ឋានទទួលបន្ទុក ត្រូវចាត់ចែងដំណើរការពិនិត្យ និងវាយតម្លៃកម្មវិធីការងារ និងសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុរបស់អ្នកដាក់ពាក្យស្នើសុំ ឲ្យបានចប់សព្វគ្រប់ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលបានឯកសារគ្រប់គ្រាន់ពីអ្នកដាក់ពាក្យស្នើសុំ ។ ក្នុងករណីពិនិត្យឃើញថា កម្មវិធីការងារដែលបានស្នើឡើងពុំសមស្រប ឬ អ្នកស្នើសុំពុំមានសមត្ថភាពត្រឹមត្រូវ នាយកដ្ឋានទទួលបន្ទុកត្រូវរៀបចំការផ្តល់មតិ និងសេចក្តីស្នើលិខិតបដិសេធលើការផ្តល់អាជ្ញាបណ្ណស្វែងរុករក ជូនថ្នាក់ដឹកនាំក្រសួងរ៉ែ និងថាមពលពិនិត្យ និងសម្រេច និងឆ្លើយតបទៅអ្នកដាក់ពាក្យស្នើសុំវិញភ្លាមៗ បន្ទាប់ពីបានបញ្ចប់ការពិនិត្យរួចហើយ ។ ក្នុងករណីពិនិត្យឃើញថា អ្នកដាក់ពាក្យស្នើសុំមានសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុត្រឹមត្រូវ ហើយទម្រង់ប្រតិបត្តិការស្វែងរុករករ៉ែ និងកម្មវិធីការងារមានលក្ខណៈសមស្រប ដែលអាចអនុញ្ញាតឲ្យប្រព្រឹត្តិទៅបាន នាយកដ្ឋានទទួលបន្ទុកត្រូវចាត់ចែងឲ្យមានការជូនដំណឹងអំពីពាក្យស្នើសុំ ទៅមូលដ្ឋានពាក់ព័ន្ធទៅនឹងការធ្វើសុរិជានអសុរិជាន និងការតម្រូវឲ្យមានភាពអនុលោមស្របតាមបទប្បញ្ញត្តិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

២- នាយកដ្ឋានទទួលបន្ទុកត្រូវរៀបចំឲ្យមានវេទិកាសាធារណៈ ដើម្បីពិគ្រោះយោបល់ និងបំភ្លឺឆ្លើយតបចំពោះបញ្ហាផ្សេងៗដែលលើកឡើងដោយសហគមន៍ ឬអ្នកពាក់ព័ន្ធផ្សេងៗ ។ ក្រោយដំណើរការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយរួចហើយ នាយកដ្ឋានទទួលបន្ទុក ត្រូវធ្វើរបាយការណ៍បូកសរុប វាយតម្លៃ និងផ្តល់មតិអំពីបញ្ហា និងបណ្តឹងតវ៉ាទាំងអស់ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលពិនិត្យ និងសម្រេច ។ សោហ៊ុយចំណាយសម្រាប់រៀបចំវេទិកាសាធារណៈជាបន្ទុករបស់អ្នកដាក់ពាក្យស្នើសុំ ។

៣- នាយកដ្ឋានទទួលបន្ទុកត្រូវពិនិត្យ និងចាត់ចែងតម្រូវឲ្យមានភាពអនុលោមស្របតាមបទប្បញ្ញត្តិស្តីពីបរិស្ថាន ។ ក្នុងករណីចាំបាច់ និងដើម្បីជានាលើកទឹកចិត្តចំពោះការវិនិយោគ នាយកដ្ឋានទទួលបន្ទុកអាចស្នើសុំរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ចេញលិខិតផ្តល់គោលការណ៍ឯកភាពចំពោះគម្រោងស្នើសុំសិក្សាស្វែងរុករកធនធានរ៉ែជាមុន ដោយភ្ជាប់នូវលក្ខខណ្ឌតម្រូវឲ្យបំពេញបាននូវភាពអនុលោមស្របតាមបទប្បញ្ញត្តិស្តីពីបរិស្ថាន ។

៤- បន្ទាប់ពីបានពិនិត្យត្រឹមត្រូវលើភាពអនុលោមពាក់ព័ន្ធនឹងបទប្បញ្ញត្តិស្តីពីបរិស្ថាន និងការដោះស្រាយបានត្រឹមត្រូវចំពោះបញ្ហា និងបណ្តឹងតវ៉ារបស់សហគមន៍ ឬអ្នកពាក់ព័ន្ធរួចហើយ នាយកដ្ឋានទទួលបន្ទុកត្រូវដំណើរការពិនិត្យ និងចរចាជាមួយអ្នកដាក់ពាក្យស្នើសុំ ដើម្បីធ្វើការរៀបចំលក្ខខណ្ឌបន្ថែមនៃអាជ្ញាបណ្ណស្វែងរុករក និង/ឬ កិច្ចព្រមព្រៀងបន្ថែមតាមករណីចាំបាច់ ។

៥- ក្រោយការបញ្ចប់ការចរចា និងរៀបចំលក្ខខណ្ឌបន្ថែមនៃអាជ្ញាបណ្ណស្វែងរុករកហើយ នាយកដ្ឋានទទួលបន្ទុកត្រូវពិនិត្យ និងចាត់ចែងតម្រូវឲ្យមានភាពអនុលោមពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដារ និងការបង់កម្រៃអាជ្ញាបណ្ណស្វែងរុករក ឲ្យបានត្រឹមត្រូវដោយអ្នកដាក់ពាក្យស្នើសុំ។

៦- បន្ទាប់ពីបានបញ្ចប់នូវរាល់ការពិនិត្យតាមបណ្តាជំហានខាងលើបានត្រឹមត្រូវរួចរាល់ហើយ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ នាយកដ្ឋានទទួលបន្ទុកត្រូវរៀបចំឯកសាររបាយការណ៍បូកសរុបលទ្ធផលវាយតម្លៃពាក្យស្នើសុំ និងផ្តល់មតិចំពោះការផ្តល់អាជ្ញាបណ្ណស្វែងរុករក ជូនរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលពិនិត្យ និងសម្រេចក្នុងការចេញអាជ្ញាបណ្ណស្វែងរុករក ។

ទទួលបានសារាចរនេះ អគ្គនាយកដ្ឋានធនធានរ៉ែ អគ្គនាយកដ្ឋានកិច្ចការទូទៅ មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរ៉ែ និងថាមពល ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

ស៊ុយ សែម

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃសារាចរស្តីពីនីតិវិធី និងដំណើរការនៃការទទួលពាក្យស្នើសុំ ការពិនិត្យ និងវាយតម្លៃ និងការឆ្លើយតបលើពាក្យស្នើសុំអាជ្ញាបណ្ណធនធានរ៉ែសម្រាប់ស្វែងរុករកធនធានរ៉ែ

